ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល
វិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខ ០៤១ សកបយ.

ភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៩

# សារាចរ
# ស្តីពី
# ការចាត់តាំងបុគ្គលិកទំនាក់ទំនងនៅតាមរោងចក្រ សហគ្រាសកាត់ដេរ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាប លោក លោកស្រីជាម្ចាស់ និងនាយករោងចក្រ សហគ្រាសកាត់ដេរទាំងអស់ថា ក្រសួងបាន និងកំពុងសង្កេតឃើញមានវិវាទការងារមួយចំនួន កើតឡើងដោយសារខ្វះការយោគយល់អនុគ្រោះគ្នា និងខ្វះការប្រាស្រ័យទាក់ទងឱ្យបានយល់គ្នាទៅវិញទៅមករវាងនិយោជកឬតំណាងនិងកម្មករនិយោជិត ។

ក្នុងគោលបំណងសម្រួលឱ្យមានទំនាក់ទំនងគ្នាល្អរវាងភាគីទាំងពីរនៅក្នុងរោងចក្រ សហគ្រាសនោះ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈនិងយុវនីតិសម្បទា សូមកំណត់ឱ្យរោងចក្រ សហគ្រាសកាត់ដេរទាំងអស់ រៀបចំឱ្យមានបុគ្គលិកមួយរូបយ៉ាងតិចសំរាប់ទទួលខុសត្រូវដោះស្រាយសំណូមពរឬការតវ៉ាផ្សេងៗរបស់កម្មករ និយោជិត ។ បុគ្គលិករូបនេះ ត្រូវទទួលខុសត្រូវធ្វើការងារនេះជាអចិន្ត្រៃយ៍ ហើយទទួលប្រាក់ឈ្នួលពីនិយោជក ។ មុន និងចាត់តាំងបុគ្គលិករូបនេះ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ត្រូវតែពិគ្រោះយោបល់អោយបានឯកភាពគ្នាជាមួយតំណាងកម្មករ និយោជិតជាមុនសិន ដើម្បីជ្រើសរើសរកមនុស្សដែលមានជំនាញឯករាជ្យ និងអព្យាក្រឹត ។ នៅពេលដែលបុគ្គលិករូបនេះអវត្តមាន ឬក៏មានការផ្លាស់ប្តូរនិយោជកត្រូវតែពិគ្រោះយោបល់ និងតំណាងកម្មករ និយោជិត និង ផ្សព្វផ្សាយជូនកម្មករ និយោជិតបានជ្រាបអំពីអ្នកជំនួសជននោះផង ។ នៅពេលបានទទួលពាក្យតវ៉ា ឬសំណូមពរផ្សេងៗ ពីកម្មករនិយោជិតជាឯកជនក្តីតាមរយៈប្រតិភូបុគ្គលិកក្តីតាមរយៈសហជីពក្តីបុគ្គលិកនោះត្រូវតែយកពាក្យតវ៉ា ឬសំណូមពរទាំងនោះ មកពិនិត្យពិចារណា ។ បើរឿងនោះជារឿងតូចតាចហើយបានការ ប្រគល់សិទ្ធិពីនិយោជកនោះបុគ្គលិករូបនោះ ត្រូវតែដោះស្រាយបញ្ហាអោយបានល្អកល្អើនទាំងការប្រើអាកប្បកិរិយាសមរម្យទន់ភ្លន់ទាំងការពន្យល់បកស្រាយអោយសាមីដើមចោទបានយល់សំដៅទទួលបាននូវភាពសុខដុមរម្យនារវាង កម្មករ និយោជិតនិងនិយោជក ។ បើពាក្យតវ៉ាឬសំណូមពរជារឿងធំឬក៏ខ្លួនមិនអាចដោះស្រាយបានបុគ្គលិកនោះត្រូវរាយការណ៍ជូននិយោជកជាបន្ទាន់

ដើម្បីកំណត់ពេលវេលាមួយសមស្របដែលនិយោជកត្រូវជួបដោះស្រាយជាមួយកម្មករ និយោជិត ឬ តំណាងដោយផ្ទាល់។ ក្នុងការដោះស្រាយបញ្ហានេះ សាមីជនកម្មករ និយោជិតអាចពឹងពាក់ប្រតិភូបុគ្គលិក ឬពឹងពាក់សហជីពអោយជួយខ្លួនបាន។ បើការដោះស្រាយនេះនៅតែមិនបានផលទៀតនោះ ទាំងសាមីជនកម្មករនិយោជិត ទាំងនិយោជក អាចប្តឹងពីមានជាផ្លូវការទៅមន្ត្រីអធិការកិច្ចការងារ ដើម្បីជួយដោះស្រាយបន្ត។ ម្ចាស់ឬនាយករោងចក្រសហគ្រាស ត្រូវតែជូនដំណឹងទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ជាផ្លូវការពីការចាត់តាំងបុគ្គលិកអោយទទួលបន្ទុកដោះស្រាយការតវ៉ាឬសំណូមពរទាមទាររបស់កម្មករ និយោជិត ហើយត្រូវតែបិទផ្សាយជូនកម្មករ និយោជិតទាំងអស់បានដឹងច្បាស់ទាំងឈ្មោះ មុខងារ និងទីកន្លែងដែល កម្មករ និយោជិតអាចទៅជួបទាក់ទងនឹងបុគ្គលិកនោះបានដោយងាយស្រួល។ នៅពេលមានការផ្លាស់ប្តូរបុគ្គលិកនេះ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ក៏ត្រូវជូនដំណឹងទៅក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ផងដែរ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ជាម្ចាស់ និងនាយករោងចក្រ សហគ្រាសកាត់ដេរទាំងអស់ពិតជាយកចិត្តទុកដាក់បំពេញតាមការកំណត់ខាងលើរបស់ក្រសួងបានល្អប្រសើរជាមិនខាន។ ការខកខានដោយប្រការណាមួយអាចនាំឱ្យមានការចាត់វិធានការយ៉ាងតឹងរឹងពីក្រសួងដោយផ្អែកតាមច្បាប់ និងបទបញ្ជាជាធរមាន។ /-

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

<u>ចម្លងជូន:</u>

- ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- កាលប្បវត្តិ-ឯកសារ